សកម្មភាព ៖ ល្បែង លេងធ្វើឡាន

**វិទ្យាសាស្ត្រ**

ការរស់នៅប្រចាំថ្ងៃ (ការប្រើប្រាស់សម្ភារតាមបច្ចេកវិទ្យា)។

បំណិនពិចារណា (ការយល់ដឹងហេតុ និងផលតាមរយការពិសោធន៍)

**សិក្សាសង្គម**

គំនូរ និងសកម្មភាពកសាង(ការយល់ដឹង និងការពេញចិត្តចំពោះសិល្បៈតាមរយៈការបង្កើតរូបភាព)

**គោលបំណង** ៖

**(វិទ្យាសាស្ត្រ)** ប្រាប់ឈ្មោះឧបករណ៍បច្ចេកវិទ្យាសាមញ្ញដែលប្រើក្នុងជិវិតប្រចាំថ្ងៃ ។

ប្រាប់ពីសកម្មភាពដែលជះឥទ្ធិពលលើវត្ថុនានា ដូចជាកង់ឡាននឹងវិលទៅមុខ។

**(សិក្សាសង្គម)** ប្រាប់ពីរបៀប រចនា បង្កើតជារូបភាពផ្សេងៗ និងបង្ហាញពីអ្វីដែលបង្កើតឡើងបាន។

**កម្រិតសិក្សា** ៖ ទាប មធ្យម ខ្ពស់

**សៀវភៅ** ៖ ដកស្រង់ចេញពីរឿង "តើអ្នកចង់ធ្វើការងារអ្វី? "

**រយៈពេល** ៖ ៣០ នាទី

**ឧបករណ៍** ៖ ដបទឹកប្លាសស្ទីក, គម្របដប, ឈើចង្កាក់, ខ្សែអំបោះ, ញញួរ, ដែកគោល។

**ការរៀបចំ** ៖

- ចោះរន្ធនៅលើដប (ចោះនៅចំណុចខាងក្រោមល្មមអាចដាក់គម្របដបនឹងឱ្យកង់ប៉ះដីបានយ៉ាងល្អ)។
- ធ្វើទុកខ្លួនឯងមួយសម្រាប់បង្ហាញក្មេងៗទាំងអស់។
- មានសម្ភារគ្រប់គ្រាន់ ។
- រៀបចំកន្លែងដែលក្មេងៗអាចប្រើសម្ភារដូចជា ញញួរ ដែកគោល និងងាយស្រួលសម្រាប់ចោះរន្ធនៅលើដបទឹក។

សេចក្ដីណែនាំ៖

1. និយាយពីលោកគ្រូសុខដែលធ្លាប់ធ្វើជាជាងម៉ូតូ នៅក្នុងរឿង "តើអ្នកចង់ធ្វើការងារអ្វី? ។
2. ប្រាប់ក្មេងៗទាំងអស់ថាថ្ងៃនេះពួកគេនឹងក្លាយជាងម៉ាស៊ីនតែម្ដង និងពួកគេអាចធ្វើឡានដោយខ្លួនឯងបាន ។
3. បង្ហាញពួកគេពីឡានដែលអ្នកបានធ្វើរួច ។
4. ចែងក្មេងៗជា ៣ក្រុម (ដែលក្រុមនីមួយៗអាចមាន ៥-១០នាក់)

5. ចែកដបទឹកឱ្យទៅក្មេងៗម្នាក់១ ឈើចង្កាក់ ១គូ គម្របដប ៤ និងខ្សែអំបោះ តែប្រាប់ពួកគេថាកុំទាន់ប៉ះសិន ។
6. ប្រាប់ពួកគេឱ្យកាន់ដបទឹក រួចនិយាយថា នេះគឺជា**រូបរាងឡាន** ចង្កាក់២គឺជា**ភ្លៅ**របស់**ឡាន** (ធ្វើឱ្យកងឡានវិល) គម្របដបគឺជា **កង់ឡាន**តែម្តង ។
7. សរសេរពាក្យទាំង៣ (**រូបរាងឡាន ភ្លៅឡាន កង់ឡាន**) នៅលើក្តារខៀន និងឱ្យក្មេងៗថាតាម ។
8. ចាប់ផ្តើមធ្វើឡានតាមក្រុមនីមួយៗ



**<u>របៀបធ្វើឡាន៖</u>**

1. ចោះរន្ធនៅចំកណ្តាលដបទឹក (គិតថាល្មមដាក់កង់បាន)
2. ដោតចង្កាក់ចូលទៅក្នុងរន្ធដែលបានចោះ
3. ចងខ្សែជុំវិញកដប
4. ដោតចង្កាក់ទៅជាប់ជាមួយគម្របដបជាការស្រេច

9. ប្រាប់ឱ្យក្មេងទាំងអស់ជួយគ្នាបានប្រសិនបើអាចទៅរួច ។
10. អ្នកត្រូវដើរជុំវិញ ដើម្បីមើលក្មេងនឹងជួយគេប្រសិនបើពួកគេត្រូវការ ។
11. នៅពេលដែលក្មេងធ្វើរួចរាល់ហើយនោះ អ្នកត្រូវឱ្យក្មេងៗទាំងអស់អង្គុយចុះនៅកន្លែងពួកគេនឹងប្រាប់ឱ្យពួកគេរក្សាភាពស្ងៀមស្ងាត់ ។
12. ឱ្យក្មេងទាំងអស់លេងឡានដែលបានធ្វើរួច។
13. ត្រូវឱ្យក្មេងៗលេងឡានរហូតអស់ម៉ោងរួចឈប់លេងល្បែងមួយហ្នឹងជាការស្រេច។

**ការប្រែប្រួល៖**

អ្នកអាចលេងល្បែងនេះជានឹងការធ្វើជារូបអ្វីផ្សេងក៏បានដែលអ្នកគិតថាវាងាយស្រួលសម្រាប់ក្មេងៗទាំងអស់។